ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវវិធានការ
## សម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ផលិតករ និងអ្នកនាំចេញទាំងអស់ ដែលបាននិងកំពុងនាំចេញទំនិញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក មេត្តាជ្រាបថា ប្រកាសអន្តរក្រសួងស្តីពីវិធានការសម្រាប់បង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ សម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងប្រកាសស្តីពីនីតិវិធីក្នុងការស្នើសុំ និងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញសម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក នឹងអនុវត្តចាប់ពី**ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥** នេះតទៅ។

ប្រកាសទាំងពីរនេះ មានគោលបំណងបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ និងជំរុញការអនុវត្តច្បាប់ស្តីពីវិធានដើមកំណើតទំនិញប្រកបដោយតម្លាភាព សម្រាប់ការនាំចេញទំនិញមួយចំនួនពីកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ ជាមួយគ្នានេះ ផលិតករ និងអ្នកនាំចេញ **មិនតម្រូវឱ្យបង់កម្រៃសេវាសាធារណៈ** សម្រាប់ការស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញនោះឡើយ។

ប្រកាសទាំងពីរនេះ និងឯកសារគតិយុត្តពាក់ព័ន្ធអាចទាញយកបានតាម QR Code ខាងក្រោម។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកប្រព័ន្ធទូរស័ព្ទសាធារណៈក្រសួងពាណិជ្ជកម្ម លេខ១២៦៦។

អាស្រ័យហេតុនេះ សូម ផលិតករ និងអ្នកនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យបានគត់មត់។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥

សូមស្កេនដើម្បីទាញយកឯកសារ

សូមស្កេនដើម្បីទទួលបានព័ត៌មានពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

*Unofficial Translation*

# Announcement
# on
# the Implementation of Measures
# for the Export of Certain Goods to the United States

The Ministry of Commerce (MoC) would like to inform all producers and exporters who have been exporting Goods to the United States that the Inter-Ministerial Prakas on Prevention Measures of Origin Frauds for Exports of Certain Goods to the United States and the Procedures for Applying and Issuing Origin Certification Letter for the Export of Certain Goods to the United States, will be effective on **12 May 2025.**

These Prakas (Ministerial Regulations) aim to prevent origin frauds and to strengthen the transparent enforcement of Law on Rules of Origin for the exports of certain Goods to the United States market. Producers and exporters are **not required to pay public service fees** when applying for Origin Certification Letter.

Both Prakas and relevant legal documents are accessible via the QR code provided below. For further information, please contact the MOC Call Center, 1266.

In this regard, all producers and exporters to the U.S. market are urged to take due note of this information and to implement it with the utmost diligence.

*Phnom Penh, 30 April 2025*

*[Stamped]*

Scan for Documents

Scan for Commerce News